# Compost

## របៀបធ្វើជីអំពុក

សន្លឹកព័ត៌មាន

### រៀបចំឲ្យបានរួចស្រេច

១. រកទីកន្លែងរាបស្មើ មានម្លប់ នៅឆ្ងាយពីប្រភពទឹក ឬដំណាំ។
២. ធ្វើរបាំងរនាំងព័ទ្ធជុំវិញជីអំពុក ដើម្បីទប់ទឹកកុំឲ្យហៀរចេញក្រៅ។
៣. ធ្វើជញ្ជាំងសំរាប់ជីអំពុករបស់លោកអ្នក ដោយប្រើបង្គោលរបង ចន្ទល់ស្នួន លួសសំណាញ់ បន្ទះឈើ កំទេចកំទី បន្ទះលោហធាតុ ផ្ទាំងក្រណាត់ ឬបន្ទះទប់ការពារកុំឲ្យរុក្ខជាតិឥតប្រយោជន៍ដុះ។ លោកអ្នកអាចប្រើធុងចំណុះ១៦៦ លីត្រដែលមានរន្ធ (កុំប្រើធុងដែលធ្លាប់ដាក់ជាតិថ្នាំគីមី ឬប្រេងសាំង)។
៤. ត្រូវជ្រោយគំនរជីអំពុក។ លោកអ្នកអាចជ្រោយគំនរជីអំពុកដោយប្រើត្រាក់ទ័រ។ គំនរជីអំពុកតូចៗអាចជ្រោយជាមួយ ប៉ែល ឬអំបោស។
៥. គ្របគំនរជីអំពុករបស់លោកអ្នកជាមួយកម្រាល បន្ទះសំពត់ជ័រ ឈើ បន្ទះលោហធាតុ ឬទ្រនាប់ក្រាល។
៦. កាត់វត្ថុធាតុជាបំណែកតូចៗ ដោយប្រើម៉ាស៊ីនកាត់ ម៉ាស៊ីនកាត់ស្មៅ ឬកន្ត្រៃកាត់មែកឈើ។





### សារធាតុដែលត្រូវដាក់ចូលទៅក្នុងជីអំពុក

សារធាតុប្រើនៅក្នុងជីអំពុកគឺមានជាតិកាបោន និងជាតិណាយត្រូហ្ស៊ែន។ ជាតិកាបោន និងជាតិណាយត្រូហ្ស៊ែនក្នុងជីអំពុកត្រូវមានអត្រាកំរិត២៥:១។ នេះបានសេចក្តីថាលោកអ្នកត្រូវដាក់ចំនួនជាតិកាបោនទៅលើគំនរជីអំពុករបស់លោកអ្នក ច្រើនជាងជាតិណាយត្រូហ្ស៊ែន។

ជាតិកាបោនៈ សារធាតុពណ៌ត្នោត (២៥ភាគ)

- ស្បូវ
- ចំបើង
- នំប៉័ង
- គ្រាប់ធញ្ញជាតិ
- ផេះឈើ
- មែកឈើតូចៗ

ជាតិណាយត្រូហ្ស៊ែនៈ សារធាតុពណ៌បៃតង (១ភាគ)

- ជីលាមកសត្វ
- កំទេចសំណល់ផ្លែឈើ និងបន្លែ
- ស្លឹកពណ៌បៃតង
- ផ្កា
- កំទេចស្មៅដែលកាត់ចោល
- កាកសំណល់ដំណាំ

HAWKESBURY NEPEAN CATCHMENT MANAGEMENT AUTHORITY

NSW DEPARTMENT OF PRIMARY INDUSTRIES

# Compost

សារធាតុដែលមិនត្រូវដាក់ចូលទៅក្នុងជីអំពុក

កុំដាក់សាច់ ត្រី ផលិតផលទឹកដោះ គ្រាប់ឈើ និងរុក្ខជាតិ ឬលាមកឆ្កែ និងឆ្មា ទៅក្នុងជីអំពុកឲ្យសោះ។ ប្រសិនបើធ្វើជីអំពុកមិនបានត្រឹមត្រូវទេ វានឹងបណ្តាលកើតមានរុយ កណ្តុរ បាក់តេរីដែលមានគ្រោះថ្នាក់ ហើយមានក្លិនមិនល្អ។



## ការធ្វើជីអំពុកយឺតៗ

ធ្វើតាម 'ជំហានខ្លះៗក្នុងការរៀបចំធ្វើជីអំពុក' ក៏ប៉ុន្តែត្រូវជ្រោយវាតែម្តងប៉ុណ្ណោះ ក្នុង១ខែ។ ត្រូវពិនិត្យមើល ហើយស្រោចទឹកបន្ថែម ប្រសិនបើជីអំពុកស្ងួត។ ជីអំពុកយឺតត្រូវចំណាយពេល៦ខែ ទៅ២ឆ្នាំ មុននឹងយកវាទៅប្រើការបាន

ទំហំ

គំនរជីអំពុកត្រូវមានទំហំ១ម៉ែត្រគូប ឬធំជាងនេះ ដើម្បីឲ្យក្តៅដល់ផ្នែកខាងក្នុង។

## ជំហានខ្លះៗក្នុងការរៀបចំធ្វើជីអំពុក

ស្រទាប់ទី១: ដាក់បន្ថែមជាតិកាបោន (សារធាតុពណ៌ត្នោត): នៅបាតក្រោមរៀបដាក់មែកឈើតូចៗ ស្បូវ ចំបើង សំបកឈើ និងស្លឹកឈើ។

ស្រទាប់ទី២: ដាក់បន្ថែមជាតិណាយត្រូហ្សែន (សារធាតុពណ៌បៃតង) ដាក់គ្របពីលើស្រទាប់ទី១ ជាមួយសារធាតុនេះ។ លោកអ្នកអាចដាក់បន្ថែមជីលាមកសត្វ ប្រសិនបើលោកអ្នកចង់។

ស្រទាប់ទី៣: គ្របពីលើស្រទាប់ទី២ ដោយដាក់ស្បូវ និងចំបើងឲ្យបានច្រើន បន្ទាប់មកស្រោចទឹកពីលើជីអំពុកដើម្បីឲ្យវាសើម។

ស្រទាប់ទី៤: ដាក់បន្ថែមសារធាតុពណ៌ត្នោតឲ្យបានច្រើនទៀត។

ស្រទាប់ទី៥: ដាក់បន្ថែមសារធាតុពណ៌បៃតង ហើយស្រោចទឹកបន្ថែមពីលើជីអំពុក ធ្វើសារដើមឡើងវិញរហូតទាល់តែធុង ឬកន្លែងធ្វើជីអំពុកវាពេញ។

គ្របកន្លែងធ្វើជីអំពុក។

ជ្រោយជីអំពុកឲ្យបាន២ដង ក្នុង១អាទិត្យ។

រៀបធ្វើគំនរជីអំពុកថ្មី ជាជាងដាក់បន្ថែមសារធាតុលើគំនរចាស់។

## ការធ្វើជីអំពុកឱ្យបានលឿន

ធ្វើតាម 'ជំហានខ្លះៗក្នុងការរៀបចំធ្វើជីអំពុក' ក៏ប៉ុន្តែត្រូវដាក់បន្ថែមជីសួនច្បារ ជីអំពុកចាស់ៗ ឬសំរាមសត្វបសុបក្សី។ ការធ្វើដូច្នេះនឹងជួយដាក់បន្ថែមសរីរាង្គល្អៗ ហើយធ្វើឲ្យវារលួយបានលឿន។ ការធ្វើជីអំពុកបានលឿន ត្រូវចំណាយពេល៣ខែ ប្រសិនបើលោកអ្នកជ្រោយជីអំពុក២ដង ក្នុង១អាទិត្យ។ ប្រសិនបើលោកអ្នកជ្រោយវាញឹកញាប់ នុះជីអំពុកនឹងឆាប់យកទៅប្រើការបានកាន់តែឆាប់។ ស្រោចទឹកបន្ថែម ប្រសិនបើជីអំពុកស្ងួត។

© NSW DPI February 2007

For more information contact

Gosford Horticultural Institute
NSW Department of Primary Industries
Locked Bag 26 Gosford NSW 2250
ph: 02 4348 1913 fax: 02 4348 1910